**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

**សំណុំរឿងរដ្ឋប្បវេណី**

លេខ ៨៨៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩

សាលក្រមលេខ ២០ "ឆ"

ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០២០

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាដំបូងខេត្តកណ្ដាល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នា ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០

## ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

-ដើមចោទឈ្មោះ [redacted] សក្កដា ភេទស្រី អាយុ ៣១ឆ្នាំ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ លេខ០២០៥៤០៧៧៦ (០១) មានអាសយដ្ឋានផ្ទះលេខ [redacted]

ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

-ចុងចម្លើយឈ្មោះ [redacted] ចាន់ ភេទប្រុស កើតឆ្នាំ១៩៨៧ សញ្ជាតិខ្មែរ មានអាសយដ្ឋាននៅ [redacted]។

ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

### <u>អង្គហេតុ និង ចំណុចវិវាទ</u>

**១.ការទាមទាររបស់ដើមចោទ ៖**

១.១-បង្គាប់ឱ្យដើមចោទឈ្មោះ [redacted] សក្កដា និងចុងចម្លើយឈ្មោះ [redacted] ចាន់ ផ្ដាច់អនីតិសង្វាសជាមួយគ្នាតាមផ្លូវច្បាប់ ។

១.២-បង្គាប់ឱ្យដើមចោទឈ្មោះ [redacted] សក្កដា មានសិទ្ធិអំណាចមេបាចិញ្ចឹមបីបាច់ថែរក្សាកូនប្រុសឈ្មោះ [redacted] សុវណ្ណាឫទ្ធិ ។

១.៣-បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] ចាន់ ផ្ដល់អាហារកាតព្វកិច្ចចិញ្ចឹមបីបាច់ថែរក្សាកូនចំនួន៤00,000 (បួនសែន)រៀល ក្នុងមួយខែ ។

១.៤-សេចក្ដីសម្រេចនេះ មានអនុភាពអនុវត្តជាបណ្ដោះអាសន្ន ។

Scanned with CamScanner

១.៥-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

**២.ការពន្យល់ត្រួសៗអំពីរឿងក្តី**

កាលពីអំឡុងឆ្នាំ២០១៥ នាងខ្ញុំឈ្មោះ [redacted] សក្កដា បានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយឈ្មោះ [redacted] ចាន់ តាមប្រពៃណី។ ក្នុងអំឡុងពេលរួមរស់ជាមួយគ្នានេះ គឺមានកូនប្រុសម្នាក់ឈ្មោះ [redacted] សុវណ្ណាឬទ្ធិ អាយុ៤ឆ្នាំ។ បច្ចុប្បន្ននាងខ្ញុំ និងចុងចម្លើយរួមរស់ជាមួយគ្នាមិនចុះសម្រុង ដែលជាហេតុធ្វើឱ្យនាងខ្ញុំអស់មនោសញ្ចេតនាជាមួយចុងចម្លើយ។ ដោយសារមូលហេតុខាងលើ ទើបនាងខ្ញុំសូមស្នើសុំឱ្យតុលាការចេញសាលក្រមឱ្យនាងខ្ញុំបានផ្តាច់អនីតិសង្វាសជាមួយចុងចម្លើយតាមផ្លូវច្បាប់។

**៣.ចំណុចវិវាទ ៖ គ្មាន។**

**៤.ការអះអាងរបស់គូភាគី ៖**

-ដើមចោទឈ្មោះ [redacted] សក្កដា បានថ្លែងការណ៍ថា: ខ្លួននៅសុំរក្សាខ្លឹមសារនៃការទាមទារដូចមាននៅក្នុងពាក្យបណ្តឹងចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ និងខ្លឹមសារនៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៩ ទុកជាបានការដដែល។ ដែលនៅក្នុងសេចក្តីថ្លែងការណ៍នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើមចោទឯកភាពតាមការស្នើសុំរបស់ក្នុងចម្លើយ។

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ ធ្វើសេចក្តីថ្លែងការណ៍តបថា:ខ្លួនក្នុងក្តីរបស់ខ្លួនឯកភាពតាមការទាមទាររបស់ដើមចោទ និងរក្សាខ្លឹមសារនៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមហេតុផលចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៩ ទុកជាបានការដដែល។ ដែលនៅក្នុងសេចក្តីថ្លែងការណ៍នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុងចម្លើយឯកភាពលែងលះជាមួយដើមចោទ ឯកភាពប្រគល់កូនឱ្យដើមចោទជាអ្នកមានអំណាចមេបា និងសុំបង់អាហារកិច្ចចិញ្ចឹមកូនចំនួន ២០០,០០០ (ពីរសែន)រៀល ក្នុងមួយខែ ហើយចុងចម្លើយសុំយកកូនទៅលេងពីរថ្ងៃ ក្នុងមួយខែ។ ចំពោះទ្រព្យសម្បត្តិរួម និងបំណុលរួមគ្មាន។

-លោកស្រី [redacted] និងលោកស្រី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ធ្វើសេចក្តីថ្លែងការណ៍តបថា:នាងខ្ញុំសុំរក្សាខ្លឹមសារនៃការទាមទាររបស់ដើមចោទ និងសុំរក្សាខ្លឹមសារនៅក្នុងសេចក្តីថ្លែងការណ៍ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ទុកជាបានការដដែល។ ដែលនៅក្នុងសេចក្តីថ្លែងការណ៍ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ បានសំណូមពរឱ្យតុលាការចេញសាលក្រម៖

+ បង្គាប់ឱ្យដើមចោទឈ្មោះ [redacted] សក្កដា និងចុងចម្លើយឈ្មោះ [redacted] ចាន់ ផ្តាច់អនីតិសង្វាសជាមួយគ្នាតាមផ្លូវច្បាប់ ។

+បង្គាប់ឱ្យដើមចោទឈ្មោះ [redacted] សក្កដា មានសិទ្ធិអំណាចមេបាចិញ្ចឹមបីបាច់ថែរក្សាកូនប្រុសឈ្មោះ [redacted] សុវណ្ណាឬទ្ធិ ។



Scanned with CamScanner

+បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] ចាន់ ផ្តល់អាហារកាតព្វកិច្ចចិញ្ចឹមបីបាច់ថែរក្សាកូនចំនួន៤០០,០០០ (បួនសែន) រៀល ក្នុងមួយខែ ។

+សេចក្តីសម្រេចនេះ មានអនុភាពអនុវត្តជាបណ្តោះអាសន្ន។

+ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

## សំអាងហេតុ

តាមលទ្ធផលនៃការសាកសួរគូភាគី និងពិនិត្យភស្តុតាង ក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា៖

-ពាក្យបណ្តឹង ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] សក្កដា ជាដើមចោទ មានលក្ខណៈត្រឹមត្រូវ បញ្ជាក់ឱ្យឃើញថា សាលាដំបូងខេត្តកណ្តាលមានដែនសមត្ថកិច្ច ដើម្បីវិនិច្ឆ័យស្របច្បាប់នូវពាក្យបណ្តឹង ហើយចេញសាលក្រម បានតាមមាត្រា ៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

-ដើមចោទឈ្មោះ [redacted] សក្កដា និងចុងចម្លើយឈ្មោះ [redacted] ចាន់ បានរួមរស់ជាមួយគ្នា តែពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ទេ មានន័យថា គូភាគីមិនមានចំណងអាពាហ៍ពិពាហ៍ពេញលេញតាមលក្ខណៈច្បាប់ ដូច្នេះពាក្យបណ្តឹងសុំឈប់រស់នៅជាអនីតិសង្វាសរបស់ដើមចោទ គឺជាបណ្តឹងផ្ទុយនឹងច្បាប់ ដែលតុលាការអាចលើកចោល ដោយយោងតាមមាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ដោយហេតុថា គូភាគីមិនមានចំណងអាពាហ៍ពិពាហ៍ ដូច្នេះគូភាគីមានសិទ្ធិពេញលេញក្នុងការរៀបអាពាហ៍ពិពាហ៍តាមឆន្ទៈរបស់ខ្លួន ដោយគ្មានការជំទាស់ពីភាគីម្ខាងទៀតទេ ។

-គូភាគីពុំមានចំណងអាពាហ៍ពិពាហ៍នឹងគ្នាក៏ពិតមែន ប៉ុន្តែតុលាការអាចសម្រេចកំណត់អំពីអំណាចមេបា បានដោយគោរពតាមគោលការណ៍អាពាហ៍ពិពាហ៍ និងផលប្រយោជន៍កូន ។

-ក្នុងកំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ គូភាគីទាំងពីរបានបង្កើតកូនចំនួនមួយនាក់ ជាអនីតិជន ឈ្មោះ [redacted] សុវណ្ណាប្ញទ្ធិ ភេទប្រុស កើតនៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៥ មានសំបុត្រកំណើតលេខ១៣៦៥ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៥ ។ គូភាគីបានព្រមព្រៀងគ្នាសម្រេចឱ្យភាគីដើមចោទឈ្មោះ [redacted] សក្កដា ត្រូវជាម្តាយជាអ្នកមានអំណាចមេបា។ ហេតុនេះ តុលាការគប្បីសម្រេចតាមការព្រមព្រៀង ផ្អែកតាមមាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណី ដែលអនុញ្ញាតឱ្យតុលាការត្រូវកំណត់យកឪពុក ឬម្តាយ ណាម្ខាងជាអ្នកមានអំណាចមេបា។

-ចំពោះសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន ភាគីទាំងពីរបានព្រមព្រៀងឯកភាពគ្នា ដោយឱ្យចុងចម្លើយយកកូនទៅលេងខាងខ្លួនបានពីរថ្ងៃ ក្នុងមួយខែ ជារៀងរាល់ចុងខែ នៃខែនីមួយៗ។

ផ្អែកតាមមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី តុលាការគប្បីសម្រេចតាមការពិភាក្សា និងកំណត់ពីរបៀបចូលសួរសុខទុក្ខកូន ដែលភាគីបានព្រមព្រៀងគ្នា។

-ចំពោះអាហារកាតព្វកិច្ច ភាគីទាំងពីរបានព្រមព្រៀងគ្នា នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងក្នុង



Scanned with CamScanner

កំណត់ហេតុស្តីពីនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដោយកំណត់យកភាគីចុងចម្លើយឈ្មោះ [redacted] ចាន់ ជាអ្នកទទួលបន្ទុកក្នុងការផ្តល់អាហារកាតព្វកិច្ចចំនួន ២០០,០០០ (ពីរសែន)រៀល ក្នុងមួយខែ ឱ្យទៅដើមចោទឈ្មោះ [redacted] សក្កដា តាមការព្រមព្រៀង។

-ចំពោះទ្រព្យសម្បត្តិរួម និងបំណុលរួម ភូភាគីអះអាងថាពុំមានទេ គប្បីតុលាការពុំលើកយកមកពិចារណាឡើយ។

-ការសុំអនុវត្តសាលក្រមជាបណ្តោះអាសន្នរបស់ដើមចោទ តុលាការយល់ឃើញថាពុំមានភាពចាំបាច់ហេតុនេះគប្បីតុលាការសម្រេចលើកចោល។

-ប្រាក់ប្រដាប់ក្តីត្រូវអនុវត្តតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## សេចក្តីសម្រេចបញ្ចប់

១. លើកចោលការទាមទាររបស់ដើមចោទឈ្មោះ [redacted] សក្កដា ត្រង់ចំណុចសុំផ្តាច់អនីតិសង្វាស ។

២. កំណត់យកដើមចោទឈ្មោះ [redacted] សក្កដា ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] សុវណ្ណាឬទ្ធិ ភេទប្រុស កើតនៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៥ តាមការព្រមព្រៀង ។

កំណត់យកការចូលសួរសុខទុក្ខកូន ដោយឱ្យចុងចម្លើយឈ្មោះ [redacted] ចាន់ មានសិទ្ធិយកកូនទៅលេងពីរថ្ងៃ ក្នុងមួយខែ ជារៀងរាល់ចុងខែ នៃខែនីមួយៗ ហើយភាគីដែលមានអំណាចមេបាត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីម្ខាងទៀត តាមការព្រមព្រៀង ។

៣.បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] ចាន់ ទទួលបន្ទុកបង់អាហារកាតព្វកិច្ចចិញ្ចឹមកូនប្រុសឈ្មោះ [redacted] សុវណ្ណាឬទ្ធិ ឱ្យដើមចោទឈ្មោះ [redacted] សក្កដា ចំនួន ២០០,០០០ (ពីរសែន)រៀល ក្នុងមួយខែ តាមការព្រមព្រៀង។

៤. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

**ចៅក្រម**

ហត្ថលេខា និងត្រា: [redacted]

---

**បានឃើញ**

**ចៅក្រម**

[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ៦កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

កណ្តាល,ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner